# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## អនុស្សរណៈនៃការយោគយល់គ្នា ស្ដីពីកិច្ចសហប្រតិបត្តិការ
## រវាង
## អង្គភាពប្រឆាំងអំពើពុករលួយ នៃព្រះរាជាណាចក្រកម្ពុជា
## និង
## សមាគមធុរកិច្ចជប៉ុននៅកម្ពុជា

អង្គភាពប្រឆាំងអំពើពុករលួយ នៃព្រះរាជាណាចក្រកម្ពុជា ("អ.ប.ព.") និងសមាគមធុរកិច្ចជប៉ុននៅកម្ពុជា ("JBAC") តទៅ ហៅថា "គូភាគី"៖

ដោយអនុលោមតាមច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយ ដែលបានប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១០

ដោយអនុលោមតាមច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយ ដែលបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨១១/០១៧ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១១

ដោយអនុលោមតាមអនុក្រឹត្យលេខ ០៥អនក្រ.បក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១១ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពប្រឆាំងអំពើពុករលួយ

ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ដែលពាក់ព័ន្ធផ្សេងៗទៀត របស់ព្រះរាជាណាចក្រកម្ពុជា

ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីបង្ហាញនូវការគាំទ្រទៅវិញទៅមក ទាក់ទងនឹងកិច្ចខិតខំប្រឹងប្រែងប្រកបដោយគតិបណ្ឌិតរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ និងក្នុងការអភិវឌ្ឍព្រះរាជាណាចក្រកម្ពុជា ព្រមទាំងអនុលោមតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា គូភាគីខាងលើបានចុះអនុស្សរណៈនៃការយោគយល់គ្នានេះនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ដោយទទួលស្គាល់នូវសារៈសំខាន់នៃការអភិវឌ្ឍ និងការពង្រឹងកិច្ចខិតខំប្រឹង ប្រែងក្នុងកិច្ចសហការដើម្បីបង្ការ និងបង្ក្រាបអំពើពុករលួយតាមរយៈកិច្ចសហប្រតិបត្តិការ ប្រកបដោយប្រសិទ្ធភាពរវាងគូភាគី

ដោយសង្កត់បញ្ជាក់ថា ការបង្កើតកិច្ចសហប្រតិបត្តិការរវាងគូភាគី នឹងពង្រឹងបន្ថែមទៀតនូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជាលក្ខណៈមិត្តភាពដែលមានស្រាប់

ដោយកត់សម្គាល់ នូវលក្ខណៈសម្បត្តិសុចរិតភាពល្អប្រសើររបស់ JBAC អ.ប.ព. សម្រេចចុះហត្ថលេខា លើអនុស្សរណៈនៃការយោគយល់គ្នាជាមួយ JBAC ដើម្បីជាគំរូដល់វិស័យឯកជនក្នុងការចូលរួមប្រយុទ្ធប្រឆាំងអំពើពុករលួយ។

បានឯកភាពគ្នាដូចខាងក្រោម ៖

## ការប្តេជ្ញាចិត្តរបស់ JBAC

- ស្របតាមការប្តេជ្ញាចិត្តជាបន្តបន្ទាប់របស់ខ្លួន ក្នុងការធ្វើជា JBAC មួយដ៏ស្អាតស្អំ និងក្នុងការកសាងនូវវប្បធម៌តម្លាភាព JBAC នឹងបន្តអនុវត្តតាមឲ្យបានពេញលេញដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងការប្រឆាំងអំពើពុករលួយ ដោយរួមបញ្ចូលទាំងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ និងក្រមព្រហ្មទណ្ឌ។

- JBAC នឹងបន្ត មិនចូលរួមក្នុងសកម្មភាពណាមួយដែលពាក់ព័ន្ធនឹងអំពើពុករលួយ ឬស៊ីសំណូកសូកប៉ាន់។ ស្របតាមការប្តេជ្ញាចិត្តនេះ JBAC នឹងបន្តអប់រំរាល់និយោជិតរបស់ខ្លួនឲ្យលើកស្ទួយនូវបរិយាកាសស្អាតស្អំ ក្នុងការប្រាស្រ័យទាក់ទងជាមួយមន្ត្រីរដ្ឋាភិបាល អ្នកផ្គត់ផ្គង់សេវាកម្ម អតិថិជន និងស្ថាប័នឬបុគ្គលផ្សេងៗដទៃទៀត។ យោងតាមគោលការណ៍បច្ចុប្បន្នរបស់ខ្លួន JBAC មានបម្រាមយ៉ាងតឹងរ៉ឹងចំពោះនិយោជិត ដែលប្រព្រឹត្តសកម្មភាពណាមួយពាក់ព័ន្ធនឹងអំពើពុករលួយ ឬស៊ីសំណូកសូកប៉ាន់ ឬសកម្មភាពណាផ្សេងទៀត ដែលត្រូវបានហាមឃាត់ និងដែលត្រូវផ្តន្ទាទោសស្របតាមច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ឬក្រមព្រហ្មទណ្ឌ ឬដែលផ្ទុយទៅនឹង បទដ្ឋានវិជ្ជាជីវៈក្នុងកម្រិតខ្ពស់បំផុតរបស់ JBAC នៅក្នុងពេលបំពេញភារកិច្ចជូន JBAC ។

- ក្នុងករណីដែល JBAC យល់ឃើញថាត្រឹមត្រូវ និងបន្ទាប់ពីបានពិចារណានូវរាល់ច្បាប់ វិធាន និងគោលការណ៍នានា ដែលមានសុពលភាពអនុវត្តន៍ចំពោះ JBAC អាចចាត់វិធានការបុរេសកម្ម ក្នុងការផ្តល់សេចក្តីជូនដំណឹងដល់ អ.ប.ព. អំពីការទាមទារឲ្យ JBAC ធ្វើការបង់ប្រាក់មិនសមស្របពីសំណាក់មន្ត្រីរដ្ឋាភិបាល អ្នកផ្គត់ផ្គង់សេវាកម្ម អតិថិជន និងស្ថាប័ន ឬបុគ្គលឯករាជ្យដទៃផ្សេងទៀត ដែលពាក់ព័ន្ធនឹងអំពើពុករលួយ ឬការស៊ីសំណូកសូកប៉ាន់ ឬបញ្ហាតម្លាភាពផ្សេងៗទៀត ដែល JBAC អាចបានដឹងឮនៅក្នុងដំណើរប្រតិបត្តិការរបស់ខ្លួន។

- JBAC នឹងចាត់តាំងបុគ្គលម្នាក់ឬច្រើននាក់ ក្នុងចំណោមនិយោជិតរបស់ខ្លួន ដើម្បីធ្វើជាជនបង្គោលសម្រាប់ទំនាក់ទំនងជាមួយជនបង្គោលដែល អ.ប.ព. ចាត់តាំងសម្រាប់ទំនាក់ទំនង។ JBAC នឹងត្រូវដាក់ជូនទៅ អ.ប.ព. ជាមុននូវលិខិតមួយក្នុងទម្រង់សមស្របដើម្បីចាត់តាំង ឬផ្លាស់ប្តូរនូវជនបង្គោលរបស់ខ្លួន។

## ការប្តេជ្ញារបស់អង្គភាពប្រឆាំងអំពើពុករលួយ

- ដោយអនុលោមតាមច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ អ.ប.ព. នឹងទទួលយកភស្តុតាងណាដែល JBAC សមាជិកនៃ JBAC និងនិយោជិតដាក់ជូន ហើយនិងចាប់ផ្តើមធ្វើការស៊ើបអង្កេត។

- អ.ប.ព. នឹងរក្សាការសម្ងាត់ជាដាច់ខាត ចំពោះប្រភពផ្តល់ព័ត៌មានទាក់ទងនឹងអំពើពុករលួយ និងចាត់រាល់វិធានការចាំបាច់ ដើម្បីរក្សាសន្តិសុខជូនបុគ្គលដែលផ្តល់ព័ត៌មានទាក់ទងនឹងអំពើពុករលួយ។

- អ.ប.ព. នឹងខិតខំឲ្យអស់ពីលទ្ធភាព ដើម្បីផ្តល់នូវកិច្ចសហប្រតិបត្តិការជាមួយ JBAC សមាជិកនៃ JBAC និងបំពេញតាមសំណូមពរសមស្របរបស់ JBAC សមាជិកនៃ JBAC ក្នុងការចូលរួមចំណែកទប់ស្កាត់ និងបង្ក្រាបអំពើពុករលួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

- អ.ប.ព. នឹងចាត់តាំងជនបង្គោលម្នាក់ឬច្រើននាក់ ក្នុងចំណោមមន្ត្រីរបស់ខ្លួនសម្រាប់ការពិភាក្សាជាមួយ JBAC ចំពោះការស្នើសុំឱ្យ JBAC បង់ប្រាក់ដែលមានសក្តានុភាពជាការបង់ប្រាក់មិនត្រឹមត្រូវ និងប្រាស្រ័យទាក់ទងជាមួយបុគ្គលសម្រាប់ទំនាក់ទំនងដែល JBAC ចាត់តាំង។ អ.ប.ព. នឹងជូនដំណឹងដល់ JBAC ជាមុន អំពីការចាត់តាំងនេះ ឬការផ្លាស់ប្តូរណាមួយដែលអាចមាន។

ក្នុងនាមជាតំណាងពេញសិទ្ធិរបស់គូភាគីទាំងសងខាង ហត្ថលេខីខាងក្រោមបានចុះ ហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នានេះ ដើម្បីជាសក្ខីភាពនៃការព្រមព្រៀងគ្នាស្របតាមខ្លឹមសារខាងលើនេះ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០២០ ជាភាសាខ្មែរ និងភាសាអង់គ្លេសចំនួនពីរច្បាប់សម្រាប់ភាសានីមួយៗ ដោយមានសុពលភាពគតិយុត្តស្មើគ្នា ។

អនុស្សរណៈនៃការយោគយល់គ្នានេះ ត្រូវចូលជាធរមានចាប់ពីកាលបរិច្ឆេទដូចមានចែងខាងលើនេះតទៅ ។

តំណាងឲ្យ
អង្គភាពប្រឆាំងអំពើពុករលួយ

បណ្ឌិត ឱម យ៉ិនទៀង
ទេសរដ្ឋមន្ត្រី
ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ

តំណាងឲ្យ
សមាគមធុរកិច្ចជប៉ុននៅកម្ពុជា

លោក ខាន់ដា យ៉ូហ្គូ
ប្រធាននៃគណៈកម្មាធិការវិនិយោគប្រចាំ JBAC